# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីពាក្យខ្មែរមួយឃ្លាពោលថា ប្រយ័ត្នត្រីរស់ក៏រួច ទន្សាយក៏រួច ។

web site: hoksavann.org

ថ្ងៃទី៩ កក្កដា ២០០៥

ពាក្យថា ត្រីរស់ក៏រួច ទន្សាយក៏រួចនេះ កើតចេញមកពីរឿងមួយនៅក្នុងរឿងព្រេងខ្មែរ គឺតាហោរអ្នកទស្សន៍ទាយនិងតាចាស់ដូនចាស់ ដែលមានសេចក្តីសង្ខេបថា ថ្ងៃមួយ តាចាស់ដូនចាស់នាំគ្នាទៅនេសាទត្រីក្នុងបឹងក្បែរភូមិ ។ ពេលនោះ គាត់រុតបានត្រីរស់មួយ និងទន្សាយលង់ទឹកមួយ ដល់ល្ងាចត្រឡប់មកផ្ទះវិញ គាត់យកទន្សាយគ្របនឹងអង្រុតទុកនៅកណ្តាលចំការបន្លែខាងមុខផ្ទះ ឯត្រីរស់ដាក់ទ្រុងប្រោះទុកក្នុងត្រពាំងជិតចំការបន្លែក្បែរកន្លែងទុកទន្សាយ ។ លុះព្រឹកឡើង តាយាយទាំងពីរនាក់ចង់សាកល្បងឲ្យហោរទាយមើលថា តើព្រឹកនេះ យើងបានម្ហូបអ្វីបរិភោគ តើហោរទាយត្រូវឬទេ, ហោរក៏ទាយថា ព្រឹកនេះ តាយាយឯងមុខជាបានលិទ្ធប្រហុកក្នុងពាងហើយ ។ តាយាយឮហោរថាដូច្នេះក៏នឹកក្នុងចិត្តថា ហោរនេះគ្មានពូកែទេ ក៏នាំគ្នាត្រឡប់មកផ្ទះវិញ យាយប្រើតាឲ្យទៅចាប់យកត្រីពីទ្រុងទៅធ្វើជាម្ហូប តាគ្រាន់តែលូកដៃចាប់ ស្រាប់តែត្រីបំរះរួចលោតចុះត្រពាំងទៅ ។ តាក៏ស្ទុះទៅយកអង្រុតដែលគ្របទន្សាយមកដេញរុតត្រី ទន្សាយដែលនៅក្នុងអង្រុតនោះ ក៏រត់បាត់ទៅទៀត ។ តាយាយទាំងពីរនាក់ក៏បរិភោគប្រហុកក្នុងពាងដូចហោរទាយមែន ។ រឿងនេះបានជាមេរៀនថា ការធ្វើកិច្ចការអ្វីមួយត្រូវប្រុងប្រយ័ត្នដោយពិចារណាជាមុនសិន បើទោះបីការងារដែលត្រូវប្រញាប់ក៏ដោយ ក៏ត្រូវតែគិតឲ្យបានល្អិតល្អន់ដែរ ដើម្បីកុំឲ្យថ្លោះធ្លោយខូចការ កុំឲ្យដូចតាចាស់ក្នុងរឿងនេះចាប់ត្រីរស់ពីក្នុងទ្រុងដោយគ្មានការប្រុងប្រយ័ត្ន ជាកំហុសមួយដែលនាំឲ្យត្រីរស់រើខ្លួនរួច ទីពីរដោយស្ពាយត្រីរស់ពេកនិងដោយការប្រញាប់ប្រញាល់ ភ្លេចគិតថាទន្សាយនៅក្នុងអង្រុត ក៏កញ្ឆក់ទាញអង្រុតនោះមករុតត្រី ទន្សាយក៏រត់រួច រីឯត្រីក៏

ហែលទៅទឹកជ្រៅបាត់ពុំអាចរុតបានឡើយ បានជាមានពាក្យចាស់ថា ប្រយ័ត្នទន្សាយក៏រួចត្រីរស់ក៏រួច ដោយទាញយកន័យតាមរឿងនេះឯង ។

នេះជាកំហុសព្រោះធ្វើការដោយគ្មានការប្រុងប្រយ័ត្នភ្លេចស្មារតី ដូចតាចាស់ក្នុងរឿងនេះ ដែលបានជាឧទាហរណ៍មួយដ៏មានតម្លៃសំរាប់អ្នកដទៃទៀតក្នុងបញ្ហាគ្រួសារក៏ដូចជាបញ្ហាជាតិ មុននឹងសំរេចធ្វើកិច្ចការណាមួយ ទោះបីការងារនោះមានការប្រញាប់ក៏ដោយ ក៏ត្រូវគិតឲ្យម៉ត់ចត់ដែរ ដើម្បីចៀសវាងកំហុសដែលអាចកើតមាន ដូចពាក្យខ្មែរថា ត្រូវគិតមុនគូរ កុំគូរមុនគិត ព្រោះបើគូរមុនគិត នាំឲ្យមានកំហុសលុបចុះលុបឡើង នាំឲ្យយឺតទៅវិញ ក៏ដូចជាកិច្ចការផ្សេងៗដែរ បើគេធ្វើពុំបានគិតឲ្យគ្រប់ជ្រុងជ្រោយទេ ការងារខ្លះអាចខុសត្រូវធ្វើសារដើមវិញ នាំឲ្យខាតពេលហើយការងារនោះពុំបានល្អនិងត្រឹមត្រូវផង ។ បើអ្នកបើកបររថយន្ត ឬនាវា ឬអាកាសយានវិញ បើមិនប្រុងប្រយ័ត្នទេ អាចមានគ្រោះថ្នាក់ដល់អ្នកជិះ ។ ក៏ដូចជាអ្នកដឹកនាំប្រទេស បើពុំបានបំពេញមុខងារនាទីរបស់ខ្លួនជាអ្នកដឹកនាំល្អទេ គិតតែប្រយោជន៍ផ្ទាល់ខ្លួន ប្រយោជន៍បក្សពួកខ្លួន ប្រព្រឹត្តអំពើពុករលួយ និងធ្វើឲ្យស្រុកទេសវិនាស ។ អ្នកដឹកនាំខ្មែរត្រូវតែទទួលខុសត្រូវនូវមុខនាទីរបស់ខ្លួន ក្នុងកិច្ចធ្វើឲ្យជាតិមានសន្តិភាពនិងចំរើនរុងរឿង ព្រមទាំងធ្វើឲ្យមានឯកភាពជាតិ ។ បើទទួលមេរៀនពីអ្នកខាងក្រៅ ក៏ចាំបាច់យកមកពិចារណាមើល តើគំនិតដែលគេផ្តល់ឲ្យនោះ ជាគំនិតជួយប្រទេសកម្ពុជាឲ្យចំរើនលូតលាស់ ឬជាគំនិតធ្វើឲ្យប្រទេសកម្ពុជាវិនាសវិញទេ ។ គោលសំខាន់ ខ្មែរត្រូវមានជំហរខ្លួនឯង កុំពឹងគេទាំងស្រុង ព្រោះថាបើពឹងគេទាំងស្រុងដោយគ្មានជំហរខ្លួនឯងឲ្យរឹងមាំនិងឲ្យនឹងនរទេ បើមានអ្នកខាងក្រៅខ្លះពុំមានគំនិតល្អជាមួយខ្មែរ ដល់ពេលគេទាញយកប្រយោជន៍ពីខ្មែរអស់ហើយ ឬអស់ផលប្រយោជន៍ពីខ្មែរហើយ គេនឹងបោះបង់ខ្មែរចោល ទុកឲ្យខ្មែរដើរទៅតាមយថាកម្មរបស់ខ្លួន ដូចជាសង្គ្រាម៥ឆ្នាំ ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩-៧៥ មហាអំណាចមួយឈប់ជួយខ្មែរដែលប្រឆាំងនឹងកុម្មុយនិស្ត ធ្វើឲ្យខ្មែរធ្លាក់ទៅកណ្តាប់ដៃខ្មែរក្រហម ដែលធ្វើឲ្យពួកនេះកាប់សម្លាប់ប្រជាពលរដ្ឋខ្មែររាប់លាននាក់ ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបគួរនាំគ្នាពិចារណា បើខូចប្រយោជន៍ផ្ទាល់ខ្លួនដើម្បីប្រយោជន៍ជាតិ នោះបុគ្គលម្នាក់ៗនៅតែមានជីវិតរស់នៅ ព្រោះបុគ្គលមួយរូបៗជាសមាជិករបស់សង្គម ប៉ុន្តែបើស្លាប់ជាតិ បុគ្គលមួយរូបៗដែលជាសមាជិកសង្គម ក៏ត្រូវស្លាប់ដែរ ។ ពាក្យខ្មែរមួយឃ្លាពោលថា ចចើងចង់លាភវែងបាត់ធនទៅ គឺគិតតែប្រយោជន៍ផ្ទាល់ខ្លួន ធ្វើឲ្យខូចប្រយោជន៍ជាតិ បើមិនប្រុងប្រយ័ត្នទេ ធ្វើឲ្យខូចប្រយោជន៍ខ្លួនផង ខូចប្រយោជន៍ជាតិផង ដូចត្រីរស់ក៏រួចទន្សាយក៏រួចដែលបានពោលមកហើយ ។៚

⌘ ⌘

⌘